N°51/15→12/7/2015

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៤-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៣៣ ស្តីពី ការប្រោសព្រះរាជទានគោរមងារ ជូនឯកឧត្តម **សាយ ឈុំ** ជា សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ៥៦០៣

១៤-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៣៤ ស្តីពី ការប្រោសព្រះរាជទានគោរមងារ ជូនឯកឧត្តម **ស ខេង** ជា សម្តេចក្រឡាហោម **ស ខេង** ៥៦០៤

១៦-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៣៥ ស្តីពី ការតែងតាំង និងផ្តល់ឋានៈទីប្រឹក្សា ជំនួយការសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ៥ រូប ដោយមិនយកប្រាក់បៀវត្ស និងតម្លើងឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ ដល់លោកឧត្តមសេនីយ៍ត្រី **សោម សោភ័ណ** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ៥៦០៥

១៦-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៣៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២៣ រូប ៥៦០៦

១៦-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៣៧ ស្តីពី ការតម្លើងឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ ជាកិច្ចបច្ឆាមរណៈដល់សពលោកឧត្តមសេនីយ៍ត្រី **អ៊ុត សិទ្ធិ** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៥៦០៨

១៦-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៣៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់កញ្ញា **ស ជុង ស៊ីម** (SEO JUNG SIM) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ ៥៦០៩

១៦-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៣៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លូ យ៉ុងហ៊ុយ** (LUO YONGHUI) ជនជាតិចិន សញ្ជាតិចិន ៥៦១០

១៦-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៤០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ចៅ ឆុង កៃ ភីតធ័រ** (CHAU CHUNG KAI PETER) ជនជាតិចិន សញ្ជាតិចិន ៥៦១១

១៦-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៤១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លី សុង ទិក** (LEE SONG TECK) ជនជាតិម៉ាឡេស៊ី សញ្ជាតិម៉ាឡេស៊ី ៥៦១២

| | | |
|---|---|---|
| ១៦-៦-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៤២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ឈិន វ៉ៃជា** （CHEN WEIJIE）ជនជាតិចិន សញ្ជាតិចិន | ៥៦១៣ |
| ១៦-៦-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៤៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម ឧកញ៉ា លោកជំទាវ អស់លោក និងលោកស្រី ចំនួន ៥៨ រូប | ៥៦១៤ |
| ១៦-៦-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៤៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ជូនលោក Moten BØsterud | ៥៦១៦ |
| ១៦-៦-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៤៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ជូនព្រះតេជគុណសុវណ្ណប្បញ្ញោ **រស់ សាវ៉ាន់** និង ព្រះតេជគុណរក្ខិតធម្មោ **គង់ សុគុណា** | ៥៦១៧ |


## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ


| | | |
|---|---|---|
| ០១-៧-២០១៥ | -អនុក្រឹត្យលេខ ៨៣ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា | ៥៦១៨ |
| ០៨-៧-២០១៥ | -អនុក្រឹត្យលេខ ៨៤ អនក្រ.បក ស្តីពី ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់ គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក | ៥៦២០ |
| ០៨-៧-២០១៥ | -អនុក្រឹត្យលេខ ៨៥ អនក្រ.បក ស្តីពី ការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹង ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | ៥៦៣៣ |
| ២៦-៦-២០១៥ | -អនុក្រឹត្យលេខ ៦៩៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ៥៦៤១ |
| ២៩-៦-២០១៥ | -អនុក្រឹត្យលេខ ៦៩៩ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី | ៥៦៤៤ |
| ២៩-៦-២០១៥ | -អនុក្រឹត្យលេខ ៧០០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ៥៦៤៥ |
| ២៩-៦-២០១៥ | -អនុក្រឹត្យលេខ ៧០១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ៥៦៤៦ |
| ២៩-៦-២០១៥ | -អនុក្រឹត្យលេខ ៧០២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៥៦៤៧ |
| ២៩-៦-២០១៥ | -អនុក្រឹត្យលេខ ៧០៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ៥៦៤៨ |
| ២៩-៦-២០១៥ | -អនុក្រឹត្យលេខ ៧០៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៥៦៤៩ |
| ២៩-៦-២០១៥ | -អនុក្រឹត្យលេខ ៧០៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ៥៦៥០ |
| ២៩-៦-២០១៥ | -អនុក្រឹត្យលេខ ៧០៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៥៦៥២ |
| ២៩-៦-២០១៥ | -អនុក្រឹត្យលេខ ៧០៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៥៦៥៣ |
| ២៩-៦-២០១៥ | -អនុក្រឹត្យលេខ ៧០៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៥៦៥៤ |

២៩-៦-២០១៥ -អនុក្រឹត្យលេខ ៧០៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៦៥៥

២៩-៦-២០១៥ -អនុក្រឹត្យលេខ ៧១០អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៦៥៦

## ២_សេចក្តីសម្រេច

៣០-៦-២០១៥ -សេចក្តីសម្រេចលេខ ៤៩ សសរ ស្តីពី ការបង្កើតក្រុមលេខាធិការនៃក្រុមជំនួយការនៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៥៦៥៩

០២-៧-២០១៥ -សេចក្តីសម្រេចលេខ ៥០ សសរ ស្តីពី ការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៥៦៦២

## III_ការងារបណ្តាក្រសួង

## ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៧-៥-២០១៥ -ប្រកាសអន្តរក្រសួងលេខ ៦១៩ សហវ.ប្រក ស្តីពី ការបង្កើតរដ្ឋទេយ្យបុរេប្រទានសម្រាប់ឆ្នាំ ២០១៥ របស់សាកលវិទ្យាល័យមានជ័យ ៥៦៦៣

២៧-៥-២០១៥ -ប្រកាសលេខ ៦២៥ សហវ.ប្រក ស្តីពី ការបង្កើតរដ្ឋទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៥ របស់អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៥៦៦៧

២៨-៥-២០១៥ -ប្រកាសអន្តរក្រសួងលេខ ៦២៦ សហវ.ប្រក ស្តីពី ការបង្កើតរដ្ឋទេយ្យបុរេប្រទានសម្រាប់ឆ្នាំ ២០១៥ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ៥៦៧១

២៩-៥-២០១៥ -ប្រកាសអន្តរក្រសួងលេខ ៦២៩ សហវ.ប្រក ស្តីពី ការតែងតាំងរដ្ឋទេយ្យករបុរេប្រទានរបស់ក្រសួងអប់រំ យុវជន និងកីឡា នៅមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា ៥៦៧៧

២៩-៥-២០១៥ -ប្រកាសលេខ ៦៣០ សហវ.ប្រក ស្តីពី ការប្រគល់សិទ្ធិចុះហត្ថលេខា ជាអាណាប័កផ្ទេរសិទ្ធិ និងអភិបាលហិរញ្ញវត្ថុលើអាណត្តិបើកប្រាក់ "ថាមពល និងទឹក" និង "សោហ៊ុយ ប្រៃសណីយ៍ និងទូរគមនាគមន៍" ជូនឯកឧត្តមអគ្គនាយក នៃ អគ្គនាយកដ្ឋានរតនាគារជាតិ ៥៦៧៩

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

០៩-៤-២០១៥ -ប្រកាសបង្កើតរោងចក្រលេខ ១៥២ ឧស.កឧ.ប្រក.០៤ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឈុន ស៊ី អីភែរីល (ខេមបូឌា) ព្រីនធីង បង្កើតរោងចក្រ បោះពុម្ព បោកគក់ និងប៉ាក់សម្លៀកបំពាក់ ៥៦៨២

០៩-៤-២០១៥ -ប្រកាសបង្កើតរោងចក្រលេខ ១៥៣ ឧស.កឧ.ប្រក.០៤ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន កំពត អិន.អិល.ស៊ី គ្រុប បង្កើតរោងចក្រ ផលិតថ្មអារ ៥៦៨៥

២៨-៤-២០១៥ -ប្រកាសបង្កើតរោងចក្រលេខ ១៦៨ ឧស.កឧ.ប្រក.០៤ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប្រ៉ែន ខនស្ត្រាក់ហ្សិន អ៊ីនដាស់ស្ទ្រីល បង្កើតរោងចក្រ លាយបេតុង ៥៦៨៨

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៣៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។
- បានទ្រង់យល់ **ឯកឧត្តម សាយ ឈុំ** ជាអ្នកដឹកនាំដ៏ឆ្នើម ជាទីគោរពស្រឡាញ់របស់ប្រជារាស្ត្រ បានជួយដឹកនាំប្រជាជាតិកម្ពុជា តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ បានចូលរួមកសាងប្រព័ន្ធច្បាប់ សំរាប់ប្រើប្រាស់ជាឧត្តមប្រយោជន៍ដល់សង្គមជាតិ ទទួលបាននូវសន្តិភាព ស្ថិរភាព ឯកភាពជាតិ ការអភិវឌ្ឍជាតិលើគ្រប់វិស័យ ការពារលទ្ធិប្រជាធិបតេយ្យ និងមានកិច្ចសហប្រតិបត្តិការអន្តរជាតិល្អ ព្រមទាំងរក្សាបាននូវឯករាជ្យជាតិ និងបូរណភាពទឹកដី ក្រោមកិច្ចដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។
- បានទ្រង់យល់ **ឯកឧត្តម សាយ ឈុំ** ជាអ្នកដឹកនាំដ៏ឆ្នើម ជាទីគោរពស្រឡាញ់របស់ប្រជារាស្ត្រ មានស្មារតីភក្តីចំពោះរាជបល្ល័ង្ក ការពារនិងគោរពព្រះពុទ្ធសាសនា ការពារសុក្រឹតធម៌សង្គមដើម្បីនិរន្តរភាពរាជានិយម នៃព្រះរាជាណាចក្រកម្ពុជា។

ប្រោសព្រះរាជទានគោរមងារ

ឯកឧត្តម សាយ ឈុំ

ជា

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

ពរស. ១៥០៦. ៦៣៩

បានប្រថាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៥

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ៦៣/១៥ ស.រ.ចប
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៥
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រេង្ការ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៣៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។
- បានទ្រង់យល់ **ឯកឧត្តម ស ខេង** ជាអ្នកដឹកនាំដ៏ឆ្នើម ជាទីគោរពស្រឡាញ់របស់ប្រជារាស្ត្រ បានចូលរួមដឹកនាំប្រជាជាតិកម្ពុជា តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ កសាងបាននូវសន្តិភាពជាតិ ស្ថិរភាពជាតិ ឯកភាពជាតិ សេដ្ឋកិច្ចជាតិ ការអភិវឌ្ឍជាតិលើគ្រប់វិស័យ ការពារលទ្ធិប្រជាធិបតេយ្យ និងមានស្ថិរភាពសន្តិសុខសង្គមបានល្អប្រសើរ ព្រមទាំងរក្សានិងការពារបាននូវឯករាជ្យជាតិ និងបូរណភាពទឹកដី ក្រោមកិច្ចដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។
- បានទ្រង់យល់ **ឯកឧត្តម ស ខេង** ជាអ្នកដឹកនាំដ៏ឆ្នើម ជាទីគោរពស្រឡាញ់របស់ប្រជារាស្ត្រ មានស្មារតីភក្តីចំពោះរាជបល្ល័ង្ក ការពារនិងគោរពព្រះពុទ្ធសាសនា ការពារយុត្តិធម៌សង្គមដើម្បីនិរន្តរភាពរាជានិយម នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រោសព្រះរាជទានគោរមងារ**

**ឯកឧត្តម ស ខេង**

**ជា**

**សម្តេចក្រឡាហោម ស ខេង**

ពរល.១៥០៦.៦៤០

**បានឡប់ចាប់ព្រះរាជហត្ថលេខាហើយ**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខ: ...០៤១/១៥ រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មិថុនា ឆ្នាំ ២០១៥
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧត្តម គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

នស/រកត/០៦១៥/៦៣៥

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈទីប្រឹក្សា ជំនួយការ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០៥ រូប ដោយមិនយកប្រាក់បៀវត្ស :

១-ឯកឧត្តម **ឡឿង ប៊ុនឆេត** ជាទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
២-ឯកឧត្តម **សោម សោភ័ណ** ជាទីប្រឹក្សា មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
៣-ឯកឧត្តម **ស្រី អរុណរដ្ឋា** ជាជំនួយការ មានឋានៈស្មើ អគ្គនាយក
៤- ឯកឧត្តម **ហេង ហាក់ម៉ុង** ជាជំនួយការ មានឋានៈស្មើ អគ្គនាយក
៥- ឯកឧត្តម **យី ភារី** ជាជំនួយការ មានឋានៈស្មើ អគ្គនាយក ។

**មាត្រា២ :** តម្លើងឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ ដល់លោកឧត្តមសេនីយ៍ត្រី **សោម សោភ័ណ** អត្តលេខ ១២២៧៦ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ។

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រណ.១៥០៦.៦៤១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥

លេខ: ៦៦១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៣៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ទ្រង់ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ឯក **លឹម ហួរ** អត្តលេខ ១៧៤៥៦
២- លោកវរសេនីយ៍ឯក **ជួប ស៊ីនួន** អត្តលេខ ២០៤៣៧
៣- លោកវរសេនីយ៍ឯក **ពាន ចាន់ថន** អត្តលេខ ៣១៤១៤
៤- លោកវរសេនីយ៍ឯក **ជៀប សុវណ្ណា** អត្តលេខ ០៥៨៧១
៥- លោកវរសេនីយ៍ឯក **អឿ សុភាព** អត្តលេខ ០៥៨៧៩
៦- លោកវរសេនីយ៍ឯក **សុខ ប៉ុឡែន** អត្តលេខ ៧១៨៨៦
៧- លោកវរសេនីយ៍ឯក **ស៊ីម ឈាន់** អត្តលេខ ៥៥១៤៩
៨- លោកវរសេនីយ៍ឯក **ឡុង ម៉ូនីកា** អត្តលេខ ៥៥៦១០
៩- លោកវរសេនីយ៍ឯក **ហ៊ើល ធីរិទ្ធ** អត្តលេខ ៦៧០០៦
១០- លោកវរសេនីយ៍ឯក **ទុំ តន្លា** អត្តលេខ ២០៨៧៤

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១១- លោកវរសេនីយ៍ឯក **ណាយ ហឿន** អត្តលេខ ២០៤៦៦

១២- លោកវរសេនីយ៍ឯក **មាស ពេញ** អត្តលេខ ១៣១២៣

១៣- លោកវរសេនីយ៍ឯក **គឹម ច័ន្ទត្រីស្ថា** អត្តលេខ ៥៧៣០៥

១៤- លោកវរសេនីយ៍ឯក **រស់ សុខផល្គុណា** អត្តលេខ ៥៦២៤៣

១៥- លោកវរសេនីយ៍ឯក **សូ សារ៉ាត់** អត្តលេខ ០៧២៥៤

១៦- លោកវរសេនីយ៍ឯក **ធន់ ប៊ុនថុល** អត្តលេខ ២០៤៣៨

១៧- លោកវរសេនីយ៍ឯក **គុន តារៈ** អត្តលេខ ៥៦២៦៤

១៨- កញ្ញាវរសេនីយ៍ឯក **ជា ស៊ីន** អត្តលេខ ២០៤៧៨

១៩- លោកវរសេនីយ៍ឯក **ឈឹម ថាណាចណ្ណា** អត្តលេខ ០៤៩០១

២០- លោកវរសេនីយ៍ឯក **ទុត ប៊ុនធឿន** អត្តលេខ ០៤៩០៦

២១- លោកវរសេនីយ៍ឯក **ពេជ្រ ហ៊ួន** អត្តលេខ ០៥៨៧៧

២២- លោកវរសេនីយ៍ឯក **លន ឈឿង** អត្តលេខ ០៥៥៤៨

២៣- លោកស្រីវរសេនីយ៍ឯក **គុន សុតារី** អត្តលេខ ៥៨០៤៤ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

ពារស. ១៥០៦.៦៤២

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥*

លេខៈ ៦៦៧ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៣៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ  នរោត្តម  សីហមុនី**
**សមានភូមិជាតិសាសនា  រក្ខតខត្តិយា  ខេមរារដ្ឋរាស្ត្រ  ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា  សមូហោភាស  កម្ពុជឯករាជរដ្ឋបូរណសន្តិ  សុភមង្គលា  សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ  ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជាកិច្ចបច្ឆាមរណៈដល់សពលោកឧត្តមសេនីយ៍ត្រី **អ៊ុត សិទ្ធិ** អត្តលេខ ០៦៧៩ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារ.១៥០៦.៦៤៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥*

លេខៈ ៦៦៧ ស.ណ
**សំណៅដែលមានតម្លៃជាភ្ជាប់ចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៣៩

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **ស ជុង ស៊ីម** (SEO JUNG SIM) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៦៦ នៅទីក្រុងប៊ូសាន សាធារណរដ្ឋកូរ៉េ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារស. ១៥០៦.៦៤៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥*

លេខ: ៦៥៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៣៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លូ យ៉ុងហ៊ុយ** (LUO YONGHUI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧៧ នៅខេត្តជឺជាំង សាធារណរដ្ឋប្រជាមានិតចិន ដោយសុំប្តូរឈ្មោះជា **លូ ហ៊ុយ** (LOU HUI)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.១៥០៦.៦៤៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥

លេខៈ ៦៥០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៤០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ទ្រង់ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចៅ ឈុង កៃ ភីធ័រ** (CHAU CHUNG KAI PETER) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៣៩ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល.១៥០៦.៦៤៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥*

លេខៈ ៦៥១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៤១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី សុង ឋិក** (LEE SONG TECK) ជនជាតិម៉ាឡេស៊ី សញ្ជាតិម៉ាឡេស៊ី កើតថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៧៨ នៅខេត្តស៊ីឡាង៉ រប្រទេសម៉ាឡេស៊ី។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**
**នរោត្តម សីហមុនី**

៣៩៤.១៥០៦.៦៤៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥

លេខ: ៦៥៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៦១៥/៥៤៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឈិន វ៉ៃជា** (CHEN WEIJIE) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៥ នៅខេត្តហ្សឺជាំង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារលា.១៥០៦.៥៤៨

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥*

លេខៈ ៦៥៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៤៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

**នូវ**

**ក-គ្រឿងឥស្សរិយយស ជាគុបការ :**

១-ឯកឧត្តម ឈួន ឆាត
២-ឯកឧត្តម កៅ តឹក
៣-ឯកឧត្តម តុប ចាន់ធួន
៤-ឯកឧត្តម ជេត មុំន
៥-ឯកឧត្តម ហុយ ថុល
៦-ឯកឧត្តម ឈី សាមឿង
៧-ឯកឧត្តម ទិា សារិទ្ធ
៨-ឯកឧត្តម សោ សាមឿន
៩-ឯកឧត្តម ជា សុផល
១០-ឯកឧត្តម ស៊ុន សាម៉ន
១១-ឯកឧត្តម ឡេង ចារិទ្ធ
១២-ឧកញ៉ា ទន់ ប៊ុនថៃ
១៣- ឧកញ៉ា ញ៉ក់ អ៊ឿកខួន
១៤-ឧកញ៉ា ថុល សុធី
១៥-លោកជំទាវ ប៉ាន់ ត្រាប្រូណា

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម គុណា ញឹម
២-ឧត្តមសេនីយ៍ត្រីហេង ឡាលីន
៣-វរសេនីយ៍ឯក មាឃ ស៊ុណា
៤-វរសេនីយ៍ឯក ឯក ស៊ឹម
៥-វរសេនីយ៍ឯក ឡាង សាមឿន
៦-វរសេនីយ៍ឯក ផេង គីមហ៊ាន
៧-វរសេនីយ៍ទោ រ័ត្ន សុខា
៨-វរសេនីយ៍ទោ ចោង ណារ៉េត
៩-វរសេនីយ៍ទោ ចាប ស៊ីណុន
១០-វរសេនីយ៍ទោ ចាន់ សារ៉ាត
១១-វរសេនីយ៍ទោ ជួន សុឃឿន
១២-វរសេនីយ៍ទោ គន្ធ ប៊ុនធឿន
១៣-វរសេនីយ៍ទោ ឥន្ទ សុខុន
១៤-វរសេនីយ៍ទោ ទ៉ូត យ៉ៃ
១៥-វរសេនីយ៍ត្រី តាំង ឈុន្នី
១៦-វរសេនីយ៍ត្រី ម៉ក់ អ៊ាង
១៧-វរសេនីយ៍ត្រី សេង កុសល
១៨-វរសេនីយ៍ត្រី យិត ចន្ទីម
១៩-អនុសេនីយ៍ឯក ម៉ៅ ស៊ីនិន
២០-លោក ឃី ផេង
២១-លោក សូ ផល្លី
២២-លោក ស្វាយ សុគន្ធី
២៣-អ្នកស្រី ចាន់ ថាន់នី

គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ៖

| | | | |
|---|---|---|---|
| ១-លោក | សុខ  តារា | ៥-លោក | ណារុប  រឿមណី |
| ២-លោក | ហួត  ឆាន | ៦-លោក | ផូ  ទុជ |
| ៣-លោក | ហ៊ីន  មេសាទុជ | ៧-លោក | ម៉ៅ  រតន៍ |
| ៤-លោក | សារុន  សម្បត្តិ | ៨-លោក | ខែម  ស៊ីន |

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ៖

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ត្រីឆី | សេរីវុឌ្ឍ | ៣-លោក | លាង  សុវណ្ណតារា |
| ២-វរសេនីយ៍ទោ | ពោង  ឈួនខាន់ជា | | |

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ៖

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី | សោម  សារី | ៥-វរសេនីយ៍ទោ | គក់  ផេង |
| ២-វរសេនីយ៍ទោ | ហ៊ីរ  ពិសិដ្ឋ | ៦-វរសេនីយ៍ទោ | លុយ  សោភា |
| ៣-វរសេនីយ៍ទោ | ប៉ាន់ថៃ  រំដោះ | ៧-វរសេនីយ៍ទោ | កែវ  សុវណ្ណជា |
| ៤-វរសេនីយ៍ទោ | ព្រុំ  សុចិន្តា | | |

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ៖

| | |
|---|---|
| ១-វរសេនីយ៍ឯក | គង់  ម៉ារី |
| ២-នាយចំណង់ | គង់  សុចិន្តា |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នសរ.១៥០៦.៦៤៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥

លេខៈ ៦៧៤ ស.ណ

សំណៅចំលងចេញពីច្បាប់ដើម សម្រាប់ចែកផ្សាយ

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

នស/រកត/០៦១៥/៦៤៤

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

លោក Moten BØsterud

៣៧៧.១៥០៦.៦៥០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥*

លេខៈ ៦៦៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែមិថុនាឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៤៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១-ព្រះតេជគុណសុវណ្ណប្បញ្ញោ **រស់ សាវ៉ាន់**

២-ព្រះតេជគុណរក្ខិតធម្មោ **គង់ សុគុណា**

ពរល. ១៥០៦.៦៥១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥

លេខៈ ៦៦៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :....៩៣....អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរឥណទានថវិកា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៣៦អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន៥៩៨ ៤០០ ០០០រៀល (ប្រាំរយកៅសិបប្រាំបីលានបួនរយពាន់រៀលគត់) ពីជំពូក៦៩ (ចំណាយមិនបានគ្រោងទុក)នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក៦០ (ការទិញ) ចំនួន៩ ៤០០ ០០០រៀល (ប្រាំបួនលានបួនរយពាន់រៀលគត់) និងជំពូក៦១ (សេវាកម្ម) ចំនួន៥៨៩ ០០០ ០០០រៀល (ប្រាំរយប៉ែតសិបប្រាំបួនលានរៀលគត់) ជូនក្រសួងការពារជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ចំណាយរៀបចំសន្និសីទមេបញ្ជាការកងទ័ពជើងអាកាសអាស៊ានលើកទី១២ ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ នៅខេត្តសៀមរាប។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៨ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដែលសរសេរជាអក្សរកាត់ថា " **គ. ស. ច. គ.** "។

**មាត្រា ២.-**

គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក បង្កើតឡើងក្នុងគោលបំណង៖

- ប្រមូលកម្លាំង ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ កិច្ចសហការសម្របសម្រួលរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ ជម្រុញការអនុវត្តគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឲ្យមានប្រសិទ្ធភាព សំដៅបង្ការ ទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកឲ្យបានជាអតិបរមា

- ការពារអាយុជីវិតប្រជាពលរដ្ឋ និងបង្ការការខូចខាតបាត់បង់ទ្រព្យសម្បត្តិ បរិស្ថាន ដែលបណ្តាលមកពីគ្រោះថ្នាក់ និងការប្រព្រឹត្តល្មើសច្បាប់ចរាចរណ៍ផ្លូវគោក

- ធានារក្សាឲ្យបាននូវរឹងមាំនូវសុវត្ថិភាព និងសណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោក។

## ជំពូកទី២
## រចនាសម្ព័ន្ធ និងសមាសភាព

**មាត្រា ៣.-**

**គ. ស. ច. គ.** មានអនុគណៈកម្មការមួយចំនួនជាជំនួយការដូចតទៅ៖

**ក.នៅថ្នាក់ជាតិ៖**

១- អនុគណៈកម្មការគោលនយោបាយនិងផែនការយុទ្ធសាស្ត្រសុវត្ថិភាពចរាចរណ៍ផ្លូវគោក ហៅកាត់ថា " អនុគណៈកម្មការទី១ "។

២- អនុគណៈកម្មការត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ហៅកាត់ថា " អនុគណៈកម្មការទី២ "។

**ខ.នៅថ្នាក់រាជធានី ខេត្ត** មានអនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី ខេត្ត។

**គ. ស. ច. គ.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ។

រចនាសម្ព័ន្ធរបស់ **គ. ស. ច. គ.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៤.–**

សមាសភាពថ្នាក់ជាតិមាន៖

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២- | រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៥- | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធាន |
| ៦- | អគ្គស្នងការនគរបាលជាតិ | អនុប្រធាន |
| ៧- | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨- | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៩- | រដ្ឋលេខាធិការក្រសួងអប់រំយុវជននិងកីឡា | សមាជិក |
| ១០- | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១១- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១២- | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៣- | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៤- | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៥- | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៦- | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១៧- | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៨- | រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៩- | រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ | សមាជិក |
| ២០- | រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ២១- | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២២- | អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូន | សមាជិក |
| ២៣- | អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ | សមាជិក |
| ២៤- | អគ្គលេខាធិការកាកបាទក្រហមកម្ពុជា | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ. ស. ច. គ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា ៥.–**

សមាសភាពអនុគណៈកម្មការនៅថ្នាក់ជាតិមាន៖

**ក.អនុគណៈកម្មការទី១៖**

| | | |
|---|---|---|
| ១. | រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | ប្រធាន |
| ២- | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣. | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- | អនុរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៥- | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦- | អគ្គនាយករងនៃអគ្គនាយកដ្ឋានដឹកជញ្ជូន | សមាជិក |
| ៧- | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៨- | អគ្គនាយករងនៃអគ្គនាយកដ្ឋានសាធារណការ | សមាជិក |
| ៩- | តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ១០- | តំណាងក្រសួងព័ត៌មាន | សមាជិក |
| ១១- | តំណាងក្រសួងអប់រំយុវជននិងកីឡា | សមាជិក |
| ១២- | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១៣- | តំណាងនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | សមាជិក |
| ១៤- | តំណាងនាយកដ្ឋានសណ្តាប់ធ្នាប់ | សមាជិក។ |

**ខ.អនុគណៈកម្មការទី២៖**

| | | |
|---|---|---|
| ១- | អគ្គស្នងការនគរបាលជាតិ | ប្រធាន |
| ២- | អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូន | អនុប្រធាន |
| ៣- | អគ្គស្នងការរងនគរបាលជាតិ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- | តំណាងក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៥- | តំណាងក្រសួងព័ត៌មាន | សមាជិក |
| ៦- | តំណាងក្រសួងអប់រំយុវជននិងកីឡា | សមាជិក |
| ៧- | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៨- | តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩- | តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១០- | ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ | សមាជិក |
| ១១- | តំណាងនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | សមាជិក |
| ១២- | តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក។ |

អនុគណៈកម្មការនៅថ្នាក់ជាតិទាំងពីរខាងលើ អាចមានសមាសភាពបន្ថែមតាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃអនុគណៈកម្មការនៅថ្នាក់ជាតិ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ. ស. ច. គ.**។

**មាត្រា ៦.-**

សមាសភាពអគ្គលេខាធិការដ្ឋាននៃ **គ. ស. ច. គ.** មានៈ

| | | |
|---|---|---|
| ១- | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | អគ្គលេខាធិការ |
| ២- | អនុរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | អគ្គលេខាធិការរង |
| ៣- | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អគ្គលេខាធិការរង |
| ៤- | អគ្គនាយករងនៃអគ្គនាយកដ្ឋានដឹកជញ្ជូន | អគ្គលេខាធិការរងអចិន្ត្រៃយ៍ |
| ៥- | តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ៦- | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៧- | អគ្គនាយករងនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | សមាជិក |
| ៨- | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ៩- | ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ | សមាជិក |
| ១០- | ប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | សមាជិក |
| ១១- | តំណាងនាយកដ្ឋានផ្លូវថ្នល់ ក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១២- | តំណាងនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | សមាជិក |
| ១៣- | តំណាងនាយកដ្ឋានសណ្តាប់ធ្នាប់ អគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៤- | តំណាងនាយកដ្ឋានការពារសុខភាព ក្រសួងសុខាភិបាល | សមាជិក |
| ១៥- | តំណាងនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា ក្រសួងអប់រំ យុវជននិងកីឡា | សមាជិក។ |

សមាសភាពជាក់ស្តែងនៃអគ្គលេខាធិការដ្ឋាន ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ. ស. ច. គ.** ។

អគ្គលេខាធិការដ្ឋាន អាចប្រើប្រាស់មន្ត្រីមួយចំនួនជាជំនួយការតាមការចាំបាច់។

អគ្គលេខាធិការដ្ឋានមានទីតាំងនៅក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា ៧.-**

សមាសភាពអនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី ខេត្ត មានៈ

| | | |
|---|---|---|
| ១- | អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធាន |
| ២- | អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- | ស្នងការនគរបាលរាជធានី ខេត្ត | អនុប្រធាន |
| ៤- | ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត | អនុប្រធាន |

៥- តំណាងស្ថាប័នអយ្យការអមសាលាដំបូងរាជធានី ខេត្ត អនុប្រធាន
៦- ស្នងការរងនគរបាលរាជធានី ខេត្ត សមាជិក
៧- មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត សមាជិក
៨- ប្រធានមន្ទីរអប់រំយុវជននិងកីឡារាជធានី ខេត្ត សមាជិក
៩- ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត សមាជិក
១០- ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត សមាជិក
១១- ប្រធានមន្ទីរព័ត៌មានរាជធានី ខេត្ត សមាជិក
១២- ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត សមាជិក
១៣- ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត សមាជិក
១៤- ប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត សមាជិក
១៥- ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត សមាជិក
១៦- ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មនិងសំណង់រាជធានី ខេត្ត សមាជិក
១៧- ប្រធានមន្ទីរឧស្សាហកម្មនិងសិប្បកម្មរាជធានី ខេត្ត សមាជិក។

សមាសភាពជាក់ស្តែងនៃអនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី ខេត្ត ត្រូវតែងតាំងដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

អនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី ខេត្តនីមួយៗ មានលេខាធិការដ្ឋានមួយជាសេនាធិការ និងមានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ជាជំនួយការ។

សមាសភាពលេខាធិការដ្ឋាន និងក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធានអនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី ខេត្ត។

**មាត្រា ៨.-**

សមាសភាពលេខាធិការដ្ឋាននៃអនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី ខេត្ត មាន៖

១- ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត ប្រធាន
២- ស្នងការរងនគរបាលរាជធានី ខេត្ត អនុប្រធានអចិន្ត្រៃយ៍
៣- អនុប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត សមាជិក
៤- អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត សមាជិក
៥- អនុប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត សមាជិក

៦- នាយកការិយាល័យចរាចរណ៍ផ្លូវគោករាជធានី ខេត្ត សមាជិក

៧- ប្រធានការិយាល័យដឹកជញ្ជូនរាជធានី ខេត្ត សមាជិក។

លេខាធិការដ្ឋាន អាចប្រើប្រាស់មន្ត្រីមួយចំនួនជាជំនួយការតាមការចាំបាច់។

លេខាធិការដ្ឋាន មានទីតាំងនៅមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត។

## ជំពូកទី៣
## តួនាទី និងភារកិច្ច

**មាត្រា ៩.-**

សមាជិក **គ. ស. ច. គ.** ត្រូវចូលរួមប្រជុំសាមញ្ញមួយឆ្នាំម្តង និងប្រជុំវិសាមញ្ញតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអចិន្ត្រៃយ៍មានសិទ្ធិអញ្ជើញ និងដឹកនាំអង្គប្រជុំតាមការប្រគល់សិទ្ធិរបស់ប្រធាន។

សមាជិកអនុគណៈកម្មការទី១ អនុគណៈកម្មការទី២ និងអនុគណៈកម្មការរាជធានី ខេត្ត ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានមួយរូបមានសិទ្ធិអញ្ជើញ និងដឹកនាំអង្គប្រជុំតាមការប្រគល់សិទ្ធិរបស់ប្រធាន។

**គ. ស. ច. គ.** មានត្រាប្រើប្រាស់ដោយឡែករបស់ **គ. ស. ច. គ.** និងមានរូបសញ្ញាសម្គាល់របស់ខ្លួន ។ គំរូត្រា និងរូបសញ្ញាសម្គាល់របស់ **គ.ស.ច.គ.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ នេះ។

អនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៅថ្នាក់រាជធានី ខេត្ត ប្រើប្រាស់ត្រាសាលារាជធានី ខេត្ត ។

**មាត្រា ១០.-**

**គ. ស. ច. គ.** មានតួនាទី និងភារកិច្ចៈ

- កសាងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រគ្រប់គ្រងសណ្តាប់ធ្នាប់សុវត្ថិភាពចរាចរណ៍ផ្លូវគោក ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច
- ចាត់តាំងអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រគ្រប់គ្រងសណ្តាប់ធ្នាប់សុវត្ថិភាពចរាចរណ៍ផ្លូវគោក
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រគ្រប់គ្រងសណ្តាប់ធ្នាប់សុវត្ថិភាពចរាចរណ៍ផ្លូវគោក
- ផ្តើមស្នើធ្វើវិសោធនកម្មច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឬ ធ្វើការកែសម្រួលលិខិតបទដ្ឋានគតិយុត្តស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- ពិនិត្យផ្តើមស្នើរាជរដ្ឋាភិបាលបំពាក់បរិក្ខារសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវ

– អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញជាតិនិងអន្តរជាតិ ឬ មន្ត្រីជាប់កិច្ចសន្យាតាមការចាំបាច់

– អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញឯកទេស ឬ ផ្នែកឯកជនឲ្យចូលរួមពិគ្រោះពិភាក្សា ផ្តល់យោបល់ និងសិក្សាស្រាវជ្រាវលើបញ្ហាសុវត្ថិភាពចរាចរណ៍ផ្លូវគោក

– លើកសរសើរចំពោះបុគ្គល ឬ ក្រុមហ៊ុន ឬ អង្គការជាដៃគូរ ឬ សប្បុរសជនដែលមានស្នាដៃជួយឧបត្ថម្ភគាំទ្រដល់បុព្វហេតុសុវត្ថិភាពចរាចរណ៍ផ្លូវគោក

– ធ្វើកិច្ចសហប្រតិបត្តិការ និងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការ សមាគម សប្បុរសជនជាតិ និងអន្តរជាតិ ដើម្បីស្វែងរកជំនួយគាំទ្រដល់ការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រគ្រប់គ្រងសណ្តាប់ធ្នាប់សុវត្ថិភាពចរាចរណ៍ផ្លូវគោក

– រៀបចំ និងគ្រប់គ្រងកញ្ចប់ថវិកាប្រចាំឆ្នាំ

– រៀបចំបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់បែបបទ និងនីតិវិធីអនុវត្តការងារ

– ធ្វើរបាយការណ៍ការងារជូនរាជរដ្ឋាភិបាលតាមកាលកំណត់។

**មាត្រា ១១.–**

អនុគណៈកម្មការទី១ មានតួនាទី និងភារកិច្ចៈ

– ធ្វើសេនាធិការជូន **គ. ស. ច. គ.** ក្នុងការពិនិត្យផ្តល់យោបល់លើការកសាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រសុវត្ថិភាពចរាចរណ៍ផ្លូវគោក

– ជម្រុញការឃោសនាអប់រំផ្សព្វផ្សាយគោលនយោបាយសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកតាមគ្រប់រូបភាព

– ធ្វើសេនាធិការជូន **គ. ស. ច. គ.** ក្នុងកិច្ចសហប្រតិបត្តិការ និងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការ សមាគម សប្បុរសជនជាតិ និងអន្តរជាតិ ដើម្បីស្វែងរកជំនួយគាំទ្រដល់ការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រគ្រប់គ្រងសណ្តាប់ធ្នាប់សុវត្ថិភាពចរាចរណ៍ផ្លូវគោក

– ផ្តើមស្នើ **គ. ស. ច. គ.** បំពាក់បរិក្ខារសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

– ផ្តើមស្នើប្រធាន **គ. ស. ច. គ.** លើកសរសើរចំពោះបុគ្គល ឬ ក្រុមហ៊ុន ឬ អង្គការជាដៃគូរ ឬ សប្បុរសជនដែលមានស្នាដៃជួយឧបត្ថម្ភគាំទ្រដល់បុព្វហេតុសុវត្ថិភាពចរាចរណ៍ផ្លូវគោក

– ធ្វើរបាយការណ៍ការងារជូន **គ. ស. ច. គ.** តាមកាលកំណត់

– អនុវត្តភារកិច្ចផ្សេងៗទៀតដែល **គ. ស. ច. គ.** ប្រគល់ឲ្យ។

**មាត្រា ១២.-**

អនុគណៈកម្មការទី២ មានតួនាទី និងភារកិច្ចៈ

- ធ្វើសេនាធិការជូន **គ. ស. ច. គ.** ក្នុងការកសាងផែនការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- ផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងផែនការសកម្មភាពអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកដល់មន្ត្រីនគរបាល
- ដឹកនាំ គ្រប់គ្រង ពង្រឹងយន្តការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងលិខិតបទដ្ឋានគតិយុត្តស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកឲ្យមានប្រសិទ្ធិភាព
- ធ្វើការស្រាវជ្រាវ ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក លិខិតបទដ្ឋានគតិយុត្តស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងមូលហេតុគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក
- ផ្តើមស្នើធ្វើវិសោធនកម្មច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឬ ធ្វើការកែសម្រួលលិខិតបទដ្ឋានគតិយុត្តស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- ធ្វើសេនាធិការជូន **គ. ស. ច. គ.** ក្នុងកិច្ចសហប្រតិបត្តិការ និងកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការ សមាគម សប្បុរសជន ជាតិ និងអន្តរជាតិ ដើម្បីស្វែងរកជំនួយគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងលិខិតបទដ្ឋានគតិយុត្តស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- ផ្តើមស្នើប្រធាន **គ. ស. ច. គ.** លើកសរសើរចំពោះបុគ្គល ឬក្រុមហ៊ុន ឬអង្គការជាដៃគូរ ឬ សប្បុរសជនដែលមានស្នាដៃជួយឧបត្ថម្ភគាំទ្រដល់បុព្វហេតុសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- ធ្វើរបាយការណ៍ការងារជូន **គ. ស. ច. គ.** តាមកាលកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀតដែល **គ. ស. ច. គ.** ប្រគល់ឲ្យ។

**មាត្រា ១៣.-**

អគ្គលេខាធិការដ្ឋាន **គ. ស. ច. គ.** មានតួនាទី និងភារកិច្ចៈ

អនុវត្តនូវរាល់សេចក្តីសម្រេចរបស់ **គ. ស. ច. គ.**

- តាមការប្រគល់សិទ្ធិរបស់ **គ. ស. ច. គ.** ធ្វើការផ្សព្វផ្សាយបទបញ្ជាដល់អង្គភាពក្រោមឱវាទ **គ. ស. ច. គ.**
- កសាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- ចាត់ចែងផ្សព្វផ្សាយអប់រំពន្យល់ណែនាំជាសាធារណៈតាមគ្រប់ប្រព័ន្ធ និងគ្រប់មធ្យោបាយដល់ប្រជាពលរដ្ឋឲ្យស្គាល់ និងយល់ដឹងអំពីច្បាប់ បទប្បញ្ញត្តិ និងសញ្ញាចរាចរណ៍

- ប្រមូលស្ថិតិយានយន្តចុះបញ្ជី និងទិន្នន័យគ្រោះថ្នាក់ចរាចរណ៍ទូទាំងប្រទេស ដើម្បីធ្វើការបូកសរុប វិភាគ ពិចារណាអំពីគោលការណ៍ ផែនការ វិធានការសុវត្ថិភាពចរាចរណ៍ផ្លូវគោក

- រៀបចំកិច្ចប្រជុំនានា និងរៀបចំរបាយការណ៍របស់ **គ. ស. ច. គ.**

- ចាត់តាំងពិធីនានារំលឹកដល់ទិវាជាតិ អន្តរជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក

- ប្រមូលផ្តុំ និងរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ **គ. ស. ច. គ.**

- បំពេញការងារបូកសរុប និងរដ្ឋបាលរបស់ **គ. ស. ច. គ.**។

ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ. ស. ច. គ.** ។

**មាត្រា ១៤.-**

អនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី ខេត្ត មានតួនាទី និងភារកិច្ចៈ

- អនុវត្តផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលដាក់ចេញដោយ **គ. ស. ច. គ.**

- កសាង និងចាត់តាំងអនុវត្តផែនការផ្សព្វផ្សាយអប់រំ និងផែនការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកក្នុងដែនសមត្ថកិច្ច

- ធ្វើការស្រាវជ្រាវ ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការផ្សព្វផ្សាយអប់រំ និងផែនការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកក្នុងដែនសមត្ថកិច្ច

- ផ្តើមស្នើបំពាក់បរិក្ខារសុវត្ថិភាពបោង្គារចនាសម្ព័ន្ធផ្លូវថ្នល់

- ស្វែងរកកិច្ចសហប្រតិបត្តិការ កិច្ចសហការ និងជំនួយគាំទ្រពីអង្គការ សមាគមសប្បុរសជនជាតិ និងអន្តរជាតិ ជួយដល់ការអនុវត្តផែនការយុទ្ធសាស្ត្រសុវត្ថិភាពចរាចរណ៍ផ្លូវគោក

- លើកសរសើរចំពោះបុគ្គល ឬ ក្រុមហ៊ុន ឬ អង្គការជាដៃគូរ ឬ សប្បុរសជនដែលមានស្នាដៃជួយឧបត្ថម្ភគាំទ្រដល់បុព្វហេតុសុវត្ថិភាពចរាចរណ៍ផ្លូវគោក

- លើកគម្រោងចំណាយប្រចាំឆ្នាំ

- ធ្វើរបាយការណ៍ការងារជូន **គ. ស. ច. គ.** តាមកាលកំណត់

- បំពេញភារកិច្ចផ្សេងៗទៀតដែល **គ. ស. ច. គ.** ប្រគល់ឲ្យ។

**មាត្រា ១៥.-**

លេខាធិការដ្ឋាននៃអនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី ខេត្ត មានតួនាទី និងភារកិច្ចៈ

– អនុវត្តនូវរាល់សេចក្តីសម្រេចរបស់អនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោក រាជធានី ខេត្ត

– តាមការប្រគល់សិទ្ធរបស់អនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី ខេត្ត ធ្វើការផ្សព្វផ្សាយបទបញ្ជាដល់អង្គភាពក្រោមឱវាទ

– ផ្សព្វផ្សាយអប់រំជាសាធារណៈដល់ប្រជាពលរដ្ឋ អំពីច្បាប់ បទប្បញ្ញត្តិ និងសញ្ញាចរាចរណ៍

– រៀបចំកិច្ចប្រជុំនានា និងរៀបចំរបាយការណ៍របស់អនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី ខេត្ត

– ប្រមូលផ្តុំ និងរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់អនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី ខេត្ត

– ប្រមូលទិន្នន័យគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកក្នុងដែនសមត្ថកិច្ច ដើម្បីធ្វើការវិភាគបម្រើដល់ការផ្សព្វផ្សាយអប់រំ និងចាត់វិធានការបង្ការទប់ស្កាត់គ្រោះថ្នាក់

– បំពេញការងារបូកសរុប និងរដ្ឋបាលរបស់អនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី ខេត្ត។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ. ស. ច. គ.**។

## ជំពូកទី៤
## ថវិការបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

**មាត្រា ១៦.–**

**គ. ស. ច. គ.** ត្រូវមានកញ្ចប់ថវិកាដោយឡែកនៅក្នុងឧបសម្ព័ន្ធនៃកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ។

**មាត្រា ១៧.–**

ប្រភពថវិការបស់ **គ. ស. ច. គ.** រួមមាន៖

– ថវិការបស់រដ្ឋ ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

– ជំនួយបរទេស

– អំណោយរបស់សប្បុរសជន ក្រុមហ៊ុនឯកជន ឬអង្គការផ្សេងៗ

– ប្រភពចំណូលស្របច្បាប់ផ្សេងៗទៀត។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៨.–**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៩.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# រចនាសម្ព័ន្ធដឹកនាំគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

**គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកគ.ស.ច.គ.**

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធាន |
| - អគ្គស្នងការនគរបាលជាតិ | អនុប្រធាន |
| - រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំយុវជននិងកីឡា | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូន | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ | សមាជិក |
| - អគ្គលេខាធិការកាកបាទក្រហមកម្ពុជា | សមាជិក |

*(មានក្រសួងចំនួន១៧ និងកាកបាទក្រហម)*

**អគ្គលេខាធិការដ្ឋាននៃ គ.ស.ច.គ.**

| | |
|---|---|
| ១.រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២.អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣.អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤.អគ្គនាយករងនៃអគ្គនាយកដ្ឋានដឹកជញ្ជូន | អនុប្រធានអចិន្ត្រៃយ៍ |
| ៥.អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៦.អគ្គនាយករងនៃអគ្គនាយកដ្ឋានរតនាគារ និងហិរញ្ញវត្ថុក្រសួងមហាផ្ទៃ | សមាជិក |
| ៧.តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ៨.តំណាងអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ | សមាជិក |
| ៩.ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ | សមាជិក |
| ១០.ប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | សមាជិក |
| ១១.តំណាងនាយកដ្ឋានផ្លូវថ្នល់ ក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១២.តំណាងនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | សមាជិក |
| ១៣.តំណាងនាយកដ្ឋានសណ្តាប់ធ្នាប់ អគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៤.តំណាងនាយកដ្ឋានការពារសុខភាព ក្រសួងសុខាភិបាល | សមាជិក |
| ១៥.តំណាងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្រ.អប់រំ យុវជន និងកីឡា | សមាជិក |

ទីតាំងនៅក្រសួងសាធារណការនិងដឹកជញ្ជូន

**អនុគណៈកម្មការគោលនយោបាយ និងផែនការយុទ្ធសាស្ត្រសុវត្ថិភាពចរាចរណ៍ផ្លូវគោក (អនុគណៈកម្មការទី១)**

| | |
|---|---|
| ១.រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២.រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣.រដ្ឋលេខាធិការក្រសួង សកដ. | អនុប្រធានអចិន្ត្រៃយ៍ |
| ៤.អនុរដ្ឋលេខាធិការ ក្រសួង សកដ. | សមាជិក |
| ៥.អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦.អគ្គនាយករងនៃអគ្គនាយកដ្ឋានដឹកជញ្ជូន | សមាជិក |
| ៧.អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៨.អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ | សមាជិក |
| ៩.តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ១០.តំណាងក្រសួងព័ត៌មាន | សមាជិក |
| ១១.តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១២.តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១៣.តំណាងនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | សមាជិក |
| ១៤.តំណាងនាយកដ្ឋានសណ្តាប់ធ្នាប់ | សមាជិក |

**អនុគណៈកម្មការត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក (អនុគណៈកម្មការទី២)**

| | |
|---|---|
| ១.អគ្គស្នងការនគរបាលជាតិ | ប្រធាន |
| ២.អគ្គនាយករងនៃអគ្គនាយកដ្ឋានដឹកជញ្ជូន | អនុប្រធាន |
| ៣.អគ្គស្នងការរងនគរបាលជាតិ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤.តំណាងក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៥.តំណាងក្រសួងព័ត៌មាន | សមាជិក |
| ៦.តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៧.តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៨.តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩.តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១០.ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ | សមាជិក |
| ១១.តំណាងនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | សមាជិក |
| ១២.តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |

**លេខាធិការដ្ឋាន**

| | |
|---|---|
| ១-ប្រធានមន្ទីរសកដ.រាជធានី ខេត្ត | ប្រធាន |
| ២-ស្នងការរងនគរបាលរាជធានីខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-អនុប្រធានមន្ទីរសកដ.រាជធានីខេត្ត | សមាជិក |
| ៤.អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | សមាជិក |
| ៥.អនុប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត | សមាជិក |
| ៦-នាយការិយាល័យចរាចរណ៍ផ្លូវគោករាជធានីខេត្ត | សមាជិក |
| ៧-ប្រធានការិយាល័យដឹកជញ្ជូនរាជធានីខេត្ត | សមាជិក |

**អនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី-ខេត្ត**

| | |
|---|---|
| អភិបាលរាជធានី-ខេត្ត | ប្រធាន |
| អភិបាលរងរាជធានី-ខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ស្នងការនគរបាល | អនុប្រធាន |
| ប្រធានមន្ទីរ សកដ. | អនុប្រធាន |
| តំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត | អនុប្រធាន |
| ស្នងការរងនគរបាលរាជធានី-ខេត្ត | សមាជិក |
| មេបញ្ជាការកងរាជអាវុធហត្ថរាជធានី-ខេត្ត | សមាជិក |
| ប្រធានមន្ទីរអប់រំយុវជន និងកីឡារាជធានី-ខេត្ត | សមាជិក |
| ប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត | សមាជិក |
| ប្រធានមន្ទីរបរិស្ថានរាជធានី-ខេត្ត | សមាជិក |
| ប្រធានមន្ទីរព័ត៌មានរាជធានី-ខេត្ត | សមាជិក |
| ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត | សមាជិក |
| ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត | សមាជិក |
| ប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត | សមាជិក |
| ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត | សមាជិក |
| ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត | សមាជិក |
| ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត | សមាជិក |

**ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក**
(ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៨៥៥.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើក្រមព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ ០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ

- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៨៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងបង្ការទប់ស្កាត់បទល្មើស និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក រក្សាសណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោក និងការពារអាយុជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅៈ
- លើកកម្ពស់ការយល់ដឹងអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បង្កើនប្រសិទ្ធភាពអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដើម្បីធ្វើឲ្យប្រសើរឡើងនូវសណ្តាប់ធ្នាប់ និងសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- កំណត់អំពើល្មើស និងចំនួនទឹកប្រាក់ ដែលត្រូវពិន័យអន្តរការណ៍។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលត្រូវពិន័យអន្តរការណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## សមត្ថកិច្ច និងសិទ្ធិរបស់នគរបាលចរាចរណ៍ផ្លូវគោក ក្នុងការពិន័យអន្តរការណ៍

**មាត្រា ៤.-**

មន្ត្រីមានសមត្ថកិច្ចធ្វើការពិន័យអន្តរការណ៍រួមមានៈ
- មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកនៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកនាយកដ្ឋានសណ្តាប់ធ្នាប់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ។

**មាត្រា ៥.-**

មន្ត្រីមានសមត្ថកិច្ចធ្វើការពិន័យអន្តរការណ៍ដែលមានចែងក្នុងមាត្រា៤ ខាងលើ មានភារកិច្ចដូចតទៅ៖

- ឃាត់ ឬ កោះហៅជនល្មើសមកពិន័យអន្តរការណ៍
- ទទួលប្រាក់ពិន័យអន្តរការណ៍ និងចេញបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ដល់ជនល្មើស
- គ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍
- គ្រប់គ្រងប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍
- ធ្វើរបាយការណ៍ស្តីពីការពិន័យអន្តរការណ៍តាមកាលកំណត់
- បញ្ជូនកំណត់ហេតុព្រមទាំងវត្ថុតាងទៅកាន់អយ្យការអមសាលាដំបូង ក្នុងករណីជនណាមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍តាមកាលកំណត់។

## ជំពូកទី៣
## អំពើល្មើស និងចំនួនទឹកប្រាក់ត្រូវពិន័យអន្តរការណ៍

**មាត្រា ៦.-**

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរទោចក្រយានយន្ត ឬ ទោចក្រយានយន្តសណ្តោងរ៉ឺម៉កឬ ត្រីចក្រយានយន្តចំនួនទឹកប្រាក់ ១៥ ០០០(មួយម៉ឺនប្រាំពាន់)រៀល អ្នកបើកបរយានយន្តធុនស្រាលចំនួនទឹកប្រាក់ ២៥ ០០០(ពីរម៉ឺនប្រាំពាន់)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ចំនួនទឹកប្រាក់ ៥០ ០០០(ប្រាំម៉ឺន)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក- អ្នកបើកបរទោចក្រយានយន្ត និងអ្នករួមដំណើរ ព្រមទាំងកុមារដែលមានអាយុពី០៣ (បី) ឆ្នាំឡើងទៅ មិនពាក់មួកសុវត្ថិភាព ឬ ពាក់មួកសុវត្ថិភាពមិនត្រឹមត្រូវតាមស្តង់ដាជាតិ ឬ ពាក់មួកសុវត្ថិភាពដោយមិនដាក់គន្លឹះខ្សែសុវត្ថិភាព។ ការពិន័យអន្តរការណ៍ករណីល្មើសនេះ ត្រូវគិតតាមចំនួនអ្នកប្រព្រឹត្តល្មើសលើកលែងកុមារ។

អ្នកបើកបរទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬ អ្នកបើកបរត្រីចក្រយានយន្ត មិនពាក់មួកសុវត្ថិភាព ឬ ពាក់មួកសុវត្ថិភាពមិនត្រឹមត្រូវតាមស្តង់ដាជាតិ ឬ ពាក់មួកសុវត្ថិភាពដោយមិនដាក់គន្លឹះខ្សែសុវត្ថិភាព។

ខ- អ្នកបើកបរយានយន្តដែលមិនបានយកភ្ជាប់តាមខ្លួននូវឯកសារដើមរួមមាន៖ បណ្ណបើកបរយានយន្ត បណ្ណសម្គាល់យានយន្ត វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ឬ លិខិតអនុញ្ញាតធ្វើអាជីវកម្មចំពោះរថយន្តដែលប្រកបអាជីវកម្មដឹកជញ្ជូន។

គ- អ្នកបើកបររថយន្តគ្រប់ប្រភេទ និងអ្នករួមដំណើរជិះកៅអីមុខនៃរថយន្ត មិនពាក់ខ្សែក្រវាត់សុវត្ថិភាព។

ឃ- អ្នកបើកបររថយន្តដាក់កុមារអាយុក្រោម ១០(ដប់) ឆ្នាំ អង្គុយនៅកៅអីខាងមុខ។

ង- អ្នកបើកបរយានយន្តឈប់ ឬ ចតល្មើសនឹងមាត្រា២៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ច- អ្នកបើកបរយានយន្តបើកបរដោយកុងទ័រល្បឿនមិនដំណើរការ។

ឆ- អ្នកបើកបរយានយន្តហួសល្បឿនកំណត់ចាប់ពី ១(មួយ) ទៅ ១៩(ដប់ប្រាំបួន) គីឡូម៉ែត្រក្នុងមួយម៉ោង។

ជ- អ្នកបើកបរយានយន្តប្រើប្រាស់ទូរស័ព្ទគ្មានឧបករណ៍សម្លេងភ្ជាប់ទំនាក់ទំនង នៅពេលកំពុងបើកបរ។

ឈ- អ្នកបើកបរយានយន្តប្រើសញ្ញាស្វរស័ព្ទមិនត្រឹមត្រូវតាមបទប្បញ្ញត្តិច្បាប់។

ញ- អ្នកបើកបរយានយន្តដឹកអ្នកដំណើរលើសចំណុះល្មើសនឹងចំណុចទី៨ មាត្រា៨ និងចំណុចទី៦ មាត្រា៥៦ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ ការពិន័យអន្តរការណ៍នេះ ត្រូវគិតតាមចំនួនអ្នកប្រព្រឹត្តល្មើស។ អំពើល្មើសចំណុចទី៨ មាត្រា៨ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក លើកលែងបានក្នុងករណីដឹកអ្នកជម្ងឺ។

**មាត្រា ៧.–**

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរទោចក្រយានយន្ត ឬ ទោចក្រយានយន្តសណ្តោងរ៉ឺម៉កឬ ត្រីចក្រយានយន្តចំនួនទឹកប្រាក់ ២០ ០០០(ពីរម៉ឺន)រៀល អ្នកបើកបរយានយន្តធុនស្រាលចំនួនទឹកប្រាក់ ៤០ ០០០(បួនម៉ឺន)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ចំនួនទឹកប្រាក់ ៧៥ ០០០(ប្រាំពីរម៉ឺនប្រាំពាន់)រៀល ចំពោះអំពើល្មើសដូចខាងក្រោមៈ

ក- អ្នកបើកបរទោចក្រយានយន្តអូសចន្ទល់លើផ្លូវថ្នល់ឬព្រលែងដៃចង្កូត ឬ លើកជើងដាក់លើដៃចង្កូត។

ខ- អ្នកបើកបរយានយន្តបង្ហោះ រេចុះរេឡើង ឆាប ឬកៀរ។

គ- អ្នកបើកបរយានយន្តរៀបចំដាក់តាំងភ្លើង និងភ្លើងសញ្ញានៃយានជំនិះ មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

ឃ- អ្នកបើកបរយានយន្តដែលម៉ាស៊ីនបញ្ចេញសម្លេងខ្លាំង ឬ ផ្សែងច្រើនខុសពីបទដ្ឋានបច្ចេកទេស។

ង- អ្នកបើកបរយានយន្តដែលគ្មាន ឬ មិនដំណើរការនូវឧបករណ៍ជូតទឹកជូតកញ្ចក់មុខ ឬ កញ្ចក់មុខ ឬ កញ្ចក់ក្រោយមានប្រេះស្រាំដែលលំបាកមើលផ្លូវ ឬ គ្មានកញ្ចក់មើលក្រោយ។

ច- អ្នកបើកបរយានយន្តហួសល្បឿនកំណត់ចាប់ពី ២០(ម្ភៃ) ទៅ ២៩(ម្ភៃប្រាំបួន)គីឡូម៉ែត្រក្នុងមួយម៉ោង។

ឆ- អ្នកបើកបររថយន្តធ្វើអាជីវកម្មដឹកអ្នកដំណើរ ឬ ដឹកទំនិញ មិនមានសញ្ញាសម្គាល់ ឬ ប្រើសញ្ញាសម្គាល់មិនត្រឹមត្រូវ។

ជ- អ្នកបើកបររថយន្តដឹកទំនិញមានគ្រោះថ្នាក់ មិនមានសញ្ញាសម្គាល់ ឬ ប្រើសញ្ញាសម្គាល់មិនត្រឹមត្រូវ។

ឈ- អ្នកបើកបរយានយន្តល្មើសនឹងបែបបទនៃការសណ្តោងយានដូចមានចែងក្នុងមាត្រា១៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ញ- អ្នកបើកបរយានយន្តដែលមិនបានប្រើភ្លើងសញ្ញាអាសន្ន ឬ មិនបានដាក់សញ្ញាត្រីកោណជាដំណឹង ក្នុងករណីដែលយានយន្តខូចមិនអាចរំកិលចេញពីទ្រូងផ្លូវបាន។ អ្នកបើកបរយានយន្តដែលមិនបានប្រើភ្លើងសញ្ញាអាសន្ន និងមិនបានដាក់សញ្ញាត្រីកោណជាដំណឹងសម្រាប់ការពារគ្រោះថ្នាក់ ក្នុងករណីដែលយានយន្តខូចមិនអាចរំកិលចេញពីទ្រូងផ្លូវបាននៅកន្លែងផ្លូវកោង ឬ ផ្លូវបត់ ឬ ផ្លូវចោត។

**មាត្រា ៨.-**

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរទោចក្រយានយន្ត ឬ ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬ ត្រីចក្រយានយន្តចំនួនទឹកប្រាក់ ២៥ ០០០(ពីរម៉ឺនប្រាំពាន់)រៀល អ្នកបើកបរយានយន្តធុនស្រាលចំនួនទឹកប្រាក់ ៥០ ០០០(ប្រាំម៉ឺន)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ចំនួនទឹកប្រាក់ ១០០ ០០០(មួយសែន)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក- អ្នកបើកបរយានយន្តបើកបរដោយពុំមានលិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬ ប្រើលិខិតធ្វើអាជីវកម្មហួសសុពលភាព។

ខ- អ្នកបើកបរយានយន្តមិនគោរពតាមលក្ខខណ្ឌសុខភាពដែលតម្រូវឲ្យពាក់វ៉ែនតា។

គ- អ្នកបើកបរយានយន្តខុសទិសដែលតម្រូវឲ្យធ្វើចរាចរណ៍ ឬ បើកបរជាន់គំនូសបង្ខតកណ្តាលទ្រូងផ្លូវ។

ឃ- អ្នកបើកបរយានយន្តហួសល្បឿនកំណត់ចាប់ពី ៣០(សាមសិប) ទៅ ៣៩(សាមសិបប្រាំបួន)គីឡូម៉ែត្រ ក្នុងមួយម៉ោង។

ង- អ្នកបើកបរយានយន្តល្មើសនឹងការជៀស ការបត់ និងការជែង។

ច- អ្នកបើកបរយានយន្តល្មើសនឹងសិទ្ធិអាទិភាពនៅផ្លូវប្រសព្វ។

ឆ- អ្នកបើកបរយានយន្តល្មើសនឹងការប្រើប្រាស់ភ្លើងបំភ្លឺ ឬ កែច្នៃភ្លើងបំភ្លឺឬភ្លើងសញ្ញានៃយានមិនត្រឹមត្រូវ។

ជ- អ្នកបើកបរយានយន្តដែលមិនមាន ឬ មិនដំណើរការភ្លើងបំភ្លឺ ឬ ភ្លើងសញ្ញានៃយាន។

ឈ- អ្នកបើកបរយានយន្តមិនគោរពភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម ឬ ក្រហមភ្លឹបភ្លែតៗ។

ញ- អ្នកបើកបរយានយន្តមិនគោរពផ្លាកសញ្ញាហាមឃាត់ ឬ ផ្លាកសញ្ញាបញ្ជា ឬ ផ្លាកសញ្ញាសិទ្ធិអាទិភាព ឬ គំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់។

ដ- អ្នកបើកបរយានយន្តប្រព្រឹត្តមិនរាងចាលនូវអំពើល្មើសស្តីពីការល្បើ ឬ ចត។

ឋ- អ្នកបើកបរយានយន្តប្រើប្រាស់សំបកកង់សឹកលើសកម្រិតកំណត់ ឬ រហែក ឬ ប្រេះ ឬ ប៉ោង។

ឌ- អ្នកបើកបរយានយន្តមិនគោរពសញ្ញាបញ្ជាចរាចរណ៍របស់ភ្នាក់ងារនគរបាលចរាចរណ៍។

ឍ- អ្នកបើកបរយានយន្តផ្ទុកទំនិញល្មើសនឹងចំណុចទី១ ទី២ ទី៣ ទី៤ ទី៥ មាត្រា៥៦ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ណ-អ្នកបើកបររថយន្តធុនធ្ងន់ដែលគ្មានរនាំងសុវត្ថិភាព ឬ មានរនាំងសុវត្ថិភាពមិនត្រឹមត្រូវតាមបណ្តោយតួរថយន្តខាងក្រោម ឬ គ្មានគន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតឺន័រ ឬ គន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតឺន័រមិនដំណើរការ។

**មាត្រា ៩.-**

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរទោចក្រយានយន្ត ឬ ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬ ត្រីចក្រយានយន្តចំនួនទឹកប្រាក់ ៣០ ០០០(បីម៉ឺន)រៀល អ្នកបើកបរយានយន្តធុនស្រាលចំនួនទឹកប្រាក់ ៦០ ០០០(ប្រាំមួយម៉ឺន)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ចំនួនទឹកប្រាក់ ១២៥ ០០០(មួយសែនពីរម៉ឺនប្រាំពាន់)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក- អ្នកបើកបរទោចក្រយានយន្ត ឬ ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬ ត្រីចក្រយានយន្តដោយគ្មានបណ្ណបើកបរ។

ខ- អ្នកបើកបរទោចក្រយានយន្ត ឬ ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬ ត្រីចក្រយានយន្តដោយគ្មានបណ្ណសម្គាល់ និង/ឬ ផ្លាកលេខ។

គ- ម្ចាស់យានយន្តមិនបានផ្ទេរកម្មសិទ្ធិយានយន្តលើសរយៈពេលកំណត់ ដែលមានចែងក្នុងមាត្រា៨៨ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ឃ- អ្នកបើកបរយានយន្តបើកបរដោយពុំមានវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ឬ ប្រើវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសហួសសុពលភាព។

ង- អ្នកបើកបរយានយន្តគ្រប់ប្រភេទដែលប្តូរម៉ាស៊ីន ឬ ប្តូរពណ៌ដោយគ្មានការអនុញ្ញាត ឬ បិទពណ៌មិនត្រឹមត្រូវតាមបណ្ណសម្គាល់យានយន្ត។

ច- អ្នកបើកបរយានយន្តប្រើប្រាស់បណ្ណបើកបរមិនត្រឹមត្រូវតាមប្រភេទយាន។

ឆ- អ្នកបើកបរយានយន្តប្រើបណ្ណបើកបរហួសសុពលភាព។

ជ- អ្នកបើកបរយានដែលមានកង់ច្រវ៉ាក់ដែកផ្ទាល់នៅលើទ្រូងផ្លូវថ្នល់ក្រាលកៅស៊ូ។

ឈ-អ្នកបើកបរយានយន្តហួសល្បឿនកំណត់ចាប់ពី ៤០(សែសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោងឡើងទៅ។

ញ- អ្នកបើកបរយានយន្តប្រើប្រាស់ផ្លាកលេខសម្គាល់យានដែលរចនាខុសពីលក្ខណៈដើម ឬ លុបលេខ ឬ បាក់ផ្លាកបាត់លេខ ឬ ដាក់សម្ភារៈ ឬ វត្ថុផ្សេងៗបាំងផ្លាកលេខ។

ជ- អ្នកបើកបរយានយន្តមានអត្រាជាតិអាកុលចាប់ពី ០,២៥(សូន្យក្បៀសម្ភៃប្រាំ) ទៅ ០,៣៩ (សូន្យក្បៀសសាមសិបប្រាំបួន)មីលីក្រាម ក្នុងមួយលីត្រខ្យល់ ឬ ចាប់ពី ០,៥(សូន្យក្បៀសប្រាំ) ទៅ ០,៧៩(សូន្យក្បៀសចិតសិបប្រាំបួន)ក្រាម ក្នុងមួយលីត្រឈាម។

ឋ- អ្នកបើកបររថយន្តឱ្យមនុស្សជិះលើយានដែលកំពុងសណ្តោងក្រៅពីអ្នកបើកបរ។

ឌ- អ្នកបើកបរយានយន្តកែច្នៃយានយន្តខុសបទដ្ឋានបច្ចេកទេស។

ឍ-អ្នកបើកបរយានយន្តប្រណាំងយានដោយគ្មានការអនុញ្ញាតលើផ្លូវសម្រាប់ធ្វើចរាចរណ៍ជាសាធារណៈ។

**មាត្រា ១០.-**

ការពិន័យអន្តរការណ៍ចំពោះអំពើល្មើសដែលមានចែងក្នុងមាត្រា៦ មាត្រា៧ មាត្រា៨ និងមាត្រា៩ ខាងលើ ត្រូវអនុវត្តចំពោះអ្នកបើកបរយានយន្តលើកលែងចំណុច "គ" នៃមាត្រា៩។

ក្នុងករណីដែលជនល្មើសមិនបានបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យ ចំនួនទឹកប្រាក់ពិន័យនេះនឹងត្រូវតម្លើងជាពីរដង បើលើសពី ៦០(ហុកសិប)ថ្ងៃ ចំនួនទឹកប្រាក់ពិន័យនេះនឹងត្រូវតម្លើងជាបីដង។ បើផុតរយៈពេល ៩០(កៅសិប)ថ្ងៃ មន្ត្រីមានសមត្ថកិច្ចត្រូវរៀបចំសំណុំឯកសារបញ្ជូនទៅអយ្យការអមសាលាដំបូង។

ទម្រង់បែបបទនៃបង្កាន់ដៃពិន័យ និងការគ្រប់គ្រងប្រាក់ចំណូលដែលបានមកពីការពិន័យ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា ១១.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់មន្ត្រីមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ មានសិទ្ធិប្តឹងតវ៉ាទៅប្រធានអង្គភាពដែលគ្រប់គ្រងលើមន្ត្រីអនុវត្តផ្ទាល់ គឺ៖

- នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវប្តឹងតវ៉ាទៅអធិការនគរបាលក្រុង ស្រុក ខណ្ឌ
- នៅថ្នាក់រាជធានី ខេត្ត ត្រូវប្តឹងតវ៉ាទៅស្នងការនគរបាលរាជធានី ខេត្ត
- នៅថ្នាក់ក្រសួង ត្រូវប្តឹងតវ៉ាទៅប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

ប្រធានអង្គភាព ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ យ៉ាងយូរ គិតពីថ្ងៃទទួលបណ្តឹង។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ប្រធានអង្គភាពខាងលើ មានសិទ្ធិប្តឹងទៅតុលាការតាមច្បាប់។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៨៥.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣  ចុះថ្ងៃទី ២៤  ខែ កញ្ញា  ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា  ឆ្នាំ ១៩៩៤  ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥  ខែ តុលា  ឆ្នាំ១៩៩៥  ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា១.**.បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនជំនួយការ និងសមាជិកក្រុមលេខា របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ចំនួន៦២រូប ដែលមានស្នាដៃល្អប្រសើរក្នុងការបំពេញ ភារកិច្ចបម្រើជាតិមាតុភូមិ  តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល  ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១-លោក | **សួន** | **និតធានី** | ឋានៈស្មើ អគ្គនាយករង |
| ២-លោកស្រី | **ឡាយ** | **លក្សី** | ឋានៈស្មើ អគ្គនាយករង |
| ៣-លោកស្រី | **ឈុំ** | **បញ្ញារដ្ឋ** | ឋានៈស្មើ អគ្គនាយករង |
| ៤-លោកស្រី | **ភុច** | **មារតី** | ឋានៈស្មើ អគ្គនាយករង |
| ៥-លោក | **អនឃួន** | **សំអួន** | ឋានៈស្មើ អគ្គនាយករង |
| ៦-លោក | **អ៊ុំ** | **ស៊ីនិត** | ឋានៈស្មើ អគ្គនាយករង |
| ៧-លោក | **ហេង** | **សុខណាង** | ឋានៈស្មើ អគ្គនាយករង |
| ៨-លោក | **ហូ** | **ចន្ទចន្សនៈ** | ឋានៈស្មើ អគ្គនាយករង |
| ៩-លោក | **ជា** | **ពិសី** | ឋានៈស្មើ អគ្គនាយករង |
| ១០-លោក | **ហ៊ិន** | **សាថ៊ុន** | ឋានៈស្មើ អគ្គនាយករង |
| ១១-លោកស្រី | **រស់** | **សុខាល** | ឋានៈស្មើ អគ្គនាយករង |
| ១២-លោកស្រី | **ឈិន** | **ឡូចម៉េង** | ឋានៈស្មើ អគ្គនាយករង |

| | | | |
|---|---|---|---|
| ១៣-លោកស្រី | សម | សុនី | ឋានៈស្មើ អគ្គនាយករង |
| ១៤-លោក | ត្រុយ | សេងហ៊ត | ឋានៈស្មើ អគ្គនាយករង |
| ១៥-លោក | ម៉ុនផា | ម៉ារីលុច | ឋានៈស្មើ អគ្គនាយករង |
| ១៦-លោក | ទ្រាក់ | ដាទីដ | ឋានៈស្មើ អគ្គនាយករង |
| ១៧-កញ្ញា | ម៉ែន | ចំន្ទដាទី | ឋានៈស្មើ អគ្គនាយករង |
| ១៨-កញ្ញា | ទ្រាម | កែវចំន្ទមុនី | ឋានៈស្មើ អគ្គនាយករង |
| ១៩-លោក | ឆាយ | ឃៀង | ឋានៈស្មើ ប្រធាននាយកដ្ឋាន |

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា

| | | | |
|---|---|---|---|
| ១-លោក | លី | ខេមរៈ | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ២-លោកស្រី | ឱ្យរ | លក្ខិណា | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៣-លោកស្រី | រស់ | សោភនី | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៤-លោកស្រី | នង | ធូក | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៥-លោកស្រី | សុទ្ធ | សុម៉ាលី | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៦-លោកស្រី | ហ៊ែម | សុវណ្ណ | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៧-លោក | នុត | លី | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៨-លោក | ជិន | ប៊ុនធឿន | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៩-លោកស្រី | នន់ | ថាវី | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ១០-លោក | សុត | ឌុច | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ១១-លោក | ឯក | ស៊ីដេ | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ១២-លោកស្រី | សេង | វណ្ណាត | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ១៣-លោក | ហៃ | វឌ្ឍី | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ១៤-លោក | សុខ | យ៉ានីមល | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ១៥-លោក | កែ | ឈុំបញ្ញា | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ១៦-លោក | មៀច | ម៉ុន | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ១៧-លោក | ប៊ុន | ចន្ទទិចិត្រ | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ១៨-លោក | នួន | មាសចំរើន | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ១៩-លោក | អ៊ុន | ម៉ានីឌុច | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ២០-លោក | រិន | រ៉ាឌុច | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ២១-លោក | សឿន | ទិបុត្រ | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ២២-លោក | សែម | សំណាង | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ២៣-លោក | ឆាង | សារិទ្ធ | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ២៤-លោក | ហេង | សុខណា | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ២៥-លោក | នឹម | ទីរៈ | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ២៦-លោកស្រី | ឈួន | រតនា | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ២៧-លោក | ឈឹម | ចាន់ណាង | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ២៨-លោកស្រី | ហួត | សុម៉ាលី | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ២៩-លោក | សុខ | សុផល | ឋានៈស្មើ ប្រធាននាយកដ្ឋាន |

| | | | |
|---|---|---|---|
| ៣០-លោក | នង | ចាន់ថុល | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៣១-លោក | ហ៊ីត | សេងហោ | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៣២-លោក | ឆេង | វណ្ណារ៉ា | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៣៣-លោក | រស្មី | ឧត្តម | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៣៤-លោក | នេត | បញ្ញា | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៣៥-លោកស្រី | ម៉ែន | ចរិយា | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៣៦-លោកស្រី | សម | ពេជ្របញ្ញា | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៣៧-លោកស្រី | ប៊ុន | ស៊ីណា | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៣៨-លោក | មុំ | ទិសុទ្ធដារ៉ូ | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៣៩-លោក | ប៉ាន់ខែម | ប៊ុនថន | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៤០-លោកស្រី | ម៉ី | ផល្លា | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៤១-លោកស្រី | សាយ | សារ៉ាមី | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៤២-លោក | ប៉ុល | សារុណា | ឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៤៣-លោក | ឃុន | ស៊ីម៉ន | ឋានៈស្មើ ប្រធាននាយកដ្ឋាន |

**មាត្រា២.** .រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៦៩៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា ១.-** បំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនគ្រូពេទ្យកូរ៉េ ចំនួន ០២រូប ដែលបានជួយជ្រោមជ្រែងកៀរគរជំនួយក្នុងការសាងសង់អគារកំពស់បីជាន់ និងបំពាក់សម្ភារៈ ពីសហគមន៍ជម្ងឺទឹកនោមផ្អែមកូរ៉េ និងអង្គការ Jeremiah 's Hope Korea សម្រាប់បម្រើការពិគ្រោះ និងព្យាបាលជម្ងឺទឹកនោមផ្អែម ស្ថិតនៅមន្ទីរពេទ្យព្រះកុសុមៈ ដូចមានរាយនាមខាងក្រោម ៖

១-លោកសាស្ត្រាចារ្យ **SUNG KOO KANG,** ex Chair of IDF-WPR and Superintend of Soon Chun Hyang Hospital

២-លោកសាស្ត្រាចារ្យ **MOON KYU LEE,** Director of Endocrine department of Samsung Medical Center and CEO Elect of KDA (Korean Diabetes Association)

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មិថុនា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...៧០.០..អនុក្រ.បក

**អនុក្រឹត្យ**

**ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**សម្រេច**

**មាត្រា ១.**- បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោកសាស្ត្រាចារ្យជំនួយ **ទូច ឃុន** នាយករងនៃមន្ទីរពេទ្យព្រះកុសុមៈដែលបានជួយជ្រោមជ្រែងកៀរគរជំនួយក្នុងការសាងសង់អគារកំពស់បីជាន់ និងបំពាក់សម្ភារ ពីសហគមន៍ជម្ងឺទឹកនោមផ្អែមកូរ៉េ និងអង្គការ Jeremiah ‘s Hope korea សម្រាប់បម្រើការពិគ្រោះ និងព្យាបាលជម្ងឺទឹកនោមផ្អែម ស្ថិតនៅមន្ទីរពេទ្យព្រះកុសុមៈ ។

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា          ជាតិ  សាសនា  ព្រះមហាក្សត្រ

លេខ: ៧០១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣  ចុះថ្ងៃទី ២៤  ខែ កញ្ញា  ឆ្នាំ ២០១៣ ស្តីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០  ខែ កក្កដា  ឆ្នាំ ១៩៩៤  ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១  ចុះថ្ងៃទី០៥  ខែ តុលា  ឆ្នាំ ១៩៩៥  ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ

## សម្រេច

**មាត្រា១.**-បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនសប្បុរសជន ចំនួន០៦រូប ដែលបានចូលរួមចំណែកទាំងស្មារតី សម្ភារៈ និងថវិកាក្នុងការកសាងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន ដើម្បីលើកកម្ពស់វិស័យព្រះពុទ្ធសាសនា និងសង្គមជាតិ ដូចជាកសាងព្រះវិហារ មហាកុដិ ខ្លោងទ្វារ សាលាឆាន់ របង បង្គន់អនាម័យ ស្រះទឹក កសាងផ្លូវលំ សាលារៀន អណ្តូងទឹក អាងចម្រោះទឹកស្អាត និងចែកអំណោយថវិកា អង្ករ សារុង ព្រមទាំងសម្ភារៈប្រើប្រាស់ជាច្រើនទៀត រួមជាមួយក្រុមការងារនៅតាមមូលដ្ឋាន នៅវត្តពោធិ៍មនោរម្យ (តាអោង) ឃុំចើងដើង ស្រុកបារាយណ៍ ខេត្តកំពង់ធំ  ដូចមាននាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោក | ជា | រដ្ឋា | សប្បុរសជននៅរាជធានីភ្នំពេញ |
| ២-លោក | អ៊ូត | ចាន់សឿន | សប្បុរសជននៅស្រុកបារាយណ៍ |
| ៣-លោក | ម៉ន | ទឹម | សប្បុរសជននៅស្វាយរៀង |
| ៤-លោក | អ៊ឹម | សុខវ៉ន | សប្បុរសជននៅស្រុកបារាយណ៍ |
| ៥-លោក | កុល | សុផាត | សប្បុរសជននៅខេត្តកំពង់ធំ |
| ៦-លោក | ស៊ុន | ចាន់ដា | សប្បុរសជននៅខេត្តកំពង់ធំ |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ  អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ

## សម្រេច

**មាត្រា១.-** បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេនិងជូនសប្បុរសជន ចំនួន០៩រូប ដែលបានចូលរួមចំណែកទាំងស្មារតី សម្ភារៈ និងថវិកាក្នុងការកសាងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន ដើម្បីលើកកម្ពស់វិស័យព្រះពុទ្ធសាសនា និងសង្គមជាតិ ដូចជាកសាងព្រះវិហារ មហាកុដិ ខ្លោងទ្វារ សាលាឆាន់ របង បង្គន់អនាម័យ ស្រះទឹក កសាងផ្លូវលំ សាលារៀន អណ្តូងទឹក អាងចម្រោះទឹកស្អាត និងចែកអំណោយថវិកា អង្ករ សារុង ព្រមទាំងសម្ភារៈប្រើប្រាស់ជាច្រើនទៀត រួមជាមួយក្រុមការងារនៅតាមមូលដ្ឋាន នៅវត្តពោធិ៍មនោរម្យ (តាអោង) ឃុំចើងដើង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | នួន ឃាង | ចៅអធិការវត្ត | បច្ច័យចំនួន ១០.១២៥ ដុល្លារ |
| ២-លោក | ដឹប អ៊ុយ | សប្បុរសជននៅភូមិពណ្ណរាយ | ថវិកាចំនួន ១០.០៩៥ ដុល្លារ |
| ៣-លោក | ចាប សារ៉េន | សប្បុរសជននៅភូមិប្រនាគ | ថវិកាចំនួន ១០.០៣៣ ដុល្លារ |
| ៤-លោក | គឿក ចេក | សប្បុរសជននៅភូមិតាអោង | ថវិកាចំនួន ១០.០២៤ ដុល្លារ |
| ៥-លោក | ញៀម ណាង | សប្បុរសជននៅភូមិបឹង | ថវិកាចំនួន ១០.០១៨ ដុល្លារ |
| ៦-លោក | ម៉ុ សុន | សប្បុរសជននៅភូមិតាអោង | ថវិកាចំនួន ១០.០១៣ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោក | គ្រូច ឡេង | សប្បុរសជននៅភូមិពន្លៃ | ថវិកាចំនួន ៥.៥២៩ ដុល្លារ |
| ២-លោក | ព្រុំ គិច | សប្បុរសជននៅភូមិតាអោង | ថវិកាចំនួន ៥.៤៩៤ ដុល្លារ |
| ៣-លោក | មាស ម៉ាង | សប្បុរសជននៅភូមិបឹង | ថវិកាចំនួន ៥.៣៥៣ ដុល្លារ |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៧០៣ អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា១.**. បំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនតំណាងអង្គការភូមិសន្តិភាពអាល្លឺម៉ង់ និងមន្ត្រីរាជការនៃមន្ទីរសុខាភិបាលខេត្ត ចំនួន០៩រូប ដែលបានខិតខំយកចិត្តទុកដាក់បំពេញការងារ និងជួយជ្រោមជ្រែងរកប្រភពថវិកា យកមកអភិវឌ្ឍន៍មន្ទីរពេទ្យបង្អែករមាសហែក ក្នុងការសាងសង់អគារ ចំនួន០១ខ្នង មានកម្ពស់០២ជាន់ ដោយមូលនិធិអង្គការភូមិសន្តិភាពអាល្លឺម៉ង់ ចំណាយថវិកាសរុបចំនួន ១៧៤.៩៧៤ ដុល្លារអាមេរិក ស្ថិតនៅមន្ទីរសុខាភិបាល ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

-លោក ជោ គីមហេង តំណាងអង្គការភូមិសន្តិភាពអាល្លឺម៉ង់

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សរឫទ្ធិ**

១-លោកវេជ្ជបណ្ឌិត ទន ថិណារ៉ា អនុប្រធានមន្ទីរសុខាភិបាលខេត្ត
២-លោកវេជ្ជបណ្ឌិត អន សុផាត អនុប្រធានមន្ទីរសុខាភិបាលខេត្ត
៣-លោកវេជ្ជបណ្ឌិត ត្លាច សុសត្ថា ប្រធានការិយាល័យស្រុកប្រតិបត្តិរមាសហែក
៤-លោកវេជ្ជបណ្ឌិត អ៊ុំ សារ៉ុន ប្រធានការិយាល័យបច្ចេកទេស
៥-លោកវេជ្ជបណ្ឌិត ហែម បេលណាលី ប្រធានការិយាល័យគណនេយ្យ
៦-លោកឱសថការី អៀ ច័ន្ទនិមល ប្រធានការិយាល័យឱសថ
៧-លោកស្រី យូ តាង ប្រធានការិយាល័យរដ្ឋបាលបុគ្គលិក
៨-លោកវេជ្ជបណ្ឌិត រាម សេដ្ឋា ប្រធានមន្ទីរពេទ្យបង្អែករមាសហែក

**មាត្រា២.**. រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៥០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការផ្ដល់មេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

### សម្រេច

**មាត្រា១.**- បំពាក់ **មេដាយមាសការងារ** ជូនលោកវេជ្ជបណ្ឌិត **គុជ ស៊ីថា** អនុប្រធានមន្ទីរសុខាភិបាលខេត្ត ដែលបានខិតខំយកចិត្តទុកដាក់បំពេញការងារ និងជួយជ្រោមជ្រែងរកប្រភពថវិកា យកមកអភិវឌ្ឍន៍មន្ទីរពេទ្យបង្អែករមាសហែក ក្នុងការសាងសង់អគារ ចំនួន០១ខ្នង មានកម្ពស់០២ជាន់ ដោយមូលនិធិអង្គការភូមិសន្តិភាពអាល្លឺម៉ង់ ស្ថិតនៅមន្ទីរសុខាភិបាលខេត្តស្វាយរៀង ។

**មាត្រា២.**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧០៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា១.** បំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូននាយកសាលា និងប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត ចំនួន១៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច លើវិស័យសុខាភិបាល កន្លងមក ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

-លោក គីមស្នូរ គីរុណ ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ចាម

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

១-លោក សុខ សុគន្ធ ប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ

២-លោក ញ៉ា ប៊ុនថន ប្រធានមន្ទីរសុខាភិបាលខេត្តកំពត

៣-លោក អោ វណ្ណថេន ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ

៤-លោក ប្រាក់ ថ៊ុន ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ឆ្នាំង

៥-លោក ឈ្លាច សុវត្ថា ប្រធានមន្ទីរសុខាភិបាលខេត្តក្រចេះ

៦-លោក កែវ សុភ័ក្ត្រា ប្រធានមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ

៧-លោកស្រី លឹម សាមាន ប្រធានមន្ទីរសុខាភិបាលខេត្តព្រះសីហនុ

៨-លោក នៅ មុីង ប្រធានមន្ទីរសុខាភិបាលខេត្តកោះកុង

៩-លោក គួយ ប៊ុនធឿន ប្រធានមន្ទីរសុខាភិបាលខេត្តកណ្តាល

| | | | |
|---|---|---|---|
| ១០-លោក | សេង | បញ្ញាឫទ្ធិ | ប្រធានមន្ទីរសុខាភិបាលខេត្តព្រៃវែង |
| ១១-លោក | ស្រី | ស៊ីន | ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ធំ |
| ១២-លោក | គ្រុស | សារ៉ាត់ | ប្រធានមន្ទីរសុខាភិបាលខេត្តសៀមរាប |
| ១៣-លោក | ថៅ | ស៊ិតធី | នាយកសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបង |
| ១៤-លោក | ម៉ែន | ម៉ារឌី | នាយកសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពង់ចាម |

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ**

| | | | |
|---|---|---|---|
| -លោក | កែវ | រដ្ឋា | ប្រធានមន្ទីរសុខាភិបាលខេត្តស្វាយរៀង |

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៧៧០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

### សម្រេច

**មាត្រា១.-** បំពាក់ **មេដាយមាសការងារ** ជូនប្រធានមន្ទីរសុខាភិបាលខេត្ត ចំនួន០៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច លើវិស័យសុខាភិបាល កន្លងមក ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោក | ប៊ុន | សួរ | ប្រធានមន្ទីរសុខាភិបាលខេត្តមណ្ឌលគីរី |
| ២-លោក | ខូយ | ឌី | ប្រធានមន្ទីរសុខាភិបាលខេត្តពោធិ៍សាត់ |
| ៣-លោក | កែវ | វណ្ណៈ | ប្រធានមន្ទីរសុខាភិបាលខេត្តត្បូងឃ្មុំ |
| ៤-លោក | អ៊ុំ | រតនា | ប្រធានមន្ទីរសុខាភិបាលខេត្តរតនគីរី |
| ៥-លោក | អ៊ុំ | សុខឿត | ប្រធានមន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង |
| ៦-លោក | ទឿង | ប៊ុនរេត | ប្រធានមន្ទីរសុខាភិបាលខេត្តបាត់ដំបង |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

